ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៩ សសរ

# សេចក្តីសម្រេច

## ស្តីពី

## ការកែសម្រួលសមាសភាពគណៈកម្មការសម្របសម្រួល និងគ្រប់គ្រងគម្រោងផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញសេចក្តីសម្រេចលេខ ២៣ សសរ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការសម្របសម្រួល និងគ្រប់គ្រងគម្រោងផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត
- យោងតាមតម្រូវការចាំបាច់

# ស ម្រេ ច

**ប្រការ ១.-**

ត្រូវបានតែងតាំង ឯកឧត្តម **ទ្រាំ អ៊ីវតឹក** រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន ជាប្រធានគណៈកម្មការសម្របសម្រួល និងគ្រប់គ្រងគម្រោងផ្លូវជាតិលេខ ៣ ពីចោមចៅ (ភ្នំពេញ) ទៅដល់ទីរួមខេត្តកំពត ជំនួស ឯកឧត្តម **អ៊ុក ចាន់** ដែលបានតែងតាំងក្នុងសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ២៣ សសរ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៤ ។

**ប្រការ ២.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ មិថុនា ឆ្នាំ ២០០៧*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល :*

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ- កាលប្បវត្តិ*